# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**
លេខ: ១១៩ គ.ជ.ប.អគ្គ

ថ្ងៃអង្គារ ១៥កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែសីហា ឆ្នាំ២០២៣

## សេចក្តីប្រកាសព័ត៌មាន
### គ.ជ.ប បានប្រកាសផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ៧:០០ព្រឹក បានប្រកាសផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ តាមប្រព័ន្ធផ្សព្វផ្សាយ ដូចខាងក្រោម៖

- ទូរទស្សន៍ជាតិកម្ពុជា (ទ.ទ.ក)
- វិទ្យុជាតិកម្ពុជា (វិទ្យុ AM 918 KHz វិទ្យុ FM 96 MHz និងវិទ្យុវត្តភ្នំ FM 105.70 MHz)
- ទីភ្នាក់ងារសារព័ត៌មានកម្ពុជា- AKP
- គេហទំព័រ គ.ជ.ប ៖ electresult.nec.gov.kh
- កម្មវិធីទូរសព្ទដៃ (App) ៖ NEC KH និង CamNEC News
- Facebook ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត National Election Committee
- YouTube ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត National Election Committee

ជាមួយគ្នានេះ គ.ជ.ប ក៏បានធ្វើការបិទផ្សាយនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅទីស្តីការ គ.ជ.ប ផងដែរ។

អនុលោមតាមមាត្រា ១៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចែងថា បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតមក គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏បាន។

ចំពោះការប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងការកំណត់បេក្ខជនជាប់ឆ្នោតនឹងប្រព្រឹត្តទៅនៅចន្លោះពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ ទៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ អាស្រ័យករណីមាន ឬគ្មានពាក្យបណ្តឹង និងករណីគ្មានការបោះឆ្នោតសាជាថ្មី។